ចំណាយថវិកាក្នុងបណ្តាក្រសួង ។

## ជំពូក ១២

## អវសានបញ្ញត្តិ

**មាត្រា ២៧ :** ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងនៅរដ្ឋបាលកណ្តាល ចាប់ពីថ្នាក់ក្រោម នាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រ សិល្បៈ

**មាត្រា ២៨ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៩ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រ សិល្បៈ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការទាំងអស់ ដែលមានការពាក់ព័ន្ធត្រូវទទួលបន្ទុករៀង ៗខ្លួនអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៧*

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

**អ៊ុង ហួត** **ហ៊ុន សែន**

* * *

## អនុក្រឹត្យលេខ ៦៣ អនក្រ.បក

## ស្តីពីការផ្ទេរឥណទាន

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣

ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម០១៩៦/១៨ ៩៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៧ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៧ របស់រាជរដ្ឋាភិបាល ស្តីពីការបែងចែកឥណទានផ្ទៃក្នុងជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៧
- បានឃើញប្រកាសលេខ ០១ ប្រ.សហវ ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ ១៩៩៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីចំណាត់ថ្នាក់ចំណូល និងចំណាយថវិកាតាមប្រភេទជំពូក ប្រការ កថាខ័ណ្ឌនៃច្បាប់ ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៤ និង ប្រកាសស្តីពីការកែប្រែ និង បំពេញបន្ថែមជាបន្តបន្ទាប់មាន : លេខ ០២២ ប្រ.សហវ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ១៩៩៤, លេខ ០០៣ ប្រ.សហវ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ ១៩៩៥, លេខ ៣២៣ ប្រក.សហវ.ថ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៥, លេខ ៣៣៖ ប្រក.សហវ.ថ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ ១៩៩៥, លេខ ០៧៖ ប្រក.សហវ.ថ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ ១៩៩៦ និងលេខ ៨០១ សហវ.ថ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ ១៩៩៦

- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សម្រេច**

មាត្រា ១ : ត្រូវបានអនុញ្ញាតអោយឥណទាន ពីជំពូក៣១ ( អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច និងវប្បធម៌ ) ចំនួន ៦៧៤.៩០០.០០០ រៀល ( ប្រាំមួយរយចិតសិបបួនលាន ប្រាំបួនរយពាន់រៀលគត់ ) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មក ជំពូក៣១ របស់ក្រសួងអប់រំយុវជន និងកីឡា ផ្នែកអប់រំ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ ។

មាត្រា ២ : ឥណទានក្នុងមាត្រា ១ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់ សំរាប់បើកផ្តល់អាហាររូបករណ៍ និង របបឧបត្ថម្ភជីវភាព អន្តេវាសិក នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និង ខេត្តក្រុង ។

មាត្រា ៣ : សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៧*

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

**អ៊ឹង ហួត** **ហ៊ុន សែន**

* * *

## អនុក្រឹត្យលេខ ៦៤ អនក្រ.បក
## ស្តីពីភាគពួកិច្ចធ្វើស្ថិតិ

* * *

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២